វិទ្យាល័យវែលលីងតុន

កម្មវិធីសិស្សអន្តរជាតិ

រដ្ឋវិចតូរីយ៉ា ប្រទេសអូស្ត្រាលី

នាយកដ្ឋានអប់រំ



សារពីនាយកសាលា

វិទ្យាល័យ Wellington Secondary College គឺជាសាលាដ៏សកម្ម និងមានដំណើរការដ៏ល្អនៅចំកណ្តាលនៃរដ្ឋអប់រំរបស់រដ្ឋវិចថូរៀ។ គ្រឿងបរិក្ខារទំនើប។ ដែលបង្កើតឡើងតាមទិសដៅរបស់យើង ស្ថិតនៅត្រឹមតែប៉ុន្មាននាទីពីបរិវេណសាកលវិទ្យាល័យម៉ូណាស្ស Monash ក្នុងសាខា Clayton ដែលជាមាគ៌ាសម្រាប់សិស្សក្នុងប្រទេស និងអន្តរជាតិជាច្រើនបន្តការសិក្សារបស់ពួកគេ។

កម្មវិធីសិស្សអន្តរជាតិដែលកំពុងរីកចម្រើនរបស់យើងនាពេលបច្ចុប្បន្ននេះ កំពុងស្វាគមន៍សិស្សជាង 100 នាក់មកពីជុំវិញពិភពលោក ជាមួយនឹងការអបអរសាទរយ៉ាងកក់ក្តៅដល់សិស្សភាគច្រើនដែលមកពីប្រទេសកម្ពុជា និងវៀតណាម។ សិស្សទាំងនេះនាំមកនូវទស្សនវិស័យវប្បធម៌ដ៏សម្បូរបែបដែលបង្កើនបទពិសោធន៍សិក្សាសម្រាប់សហគមន៍របស់យើងទាំងមូល។

បាវចនារបស់យើង — ការថែទាំ ការតស៊ូ ការរៀនសូត្រ — បង្កើតជា "មាគ៌ារបស់វិទ្យាល័យវែលលីងតុន Wellington Way" ដែលជាប្រពៃណីដ៏មានមោទនភាព ហើយដែលត្រូវបានទទួលស្គាល់ទាំងនៅក្នុងប្រទេស និងទាំងក្នុងអន្តរជាតិ។ វាបំផុសគំនិតសមាជិកគ្រប់រូបនៃវិទ្យាល័យរបស់យើងឱ្យមានគោលបំណងខ្ពស់ ទទួលយកបញ្ហាប្រឈម និងគាំទ្រគ្នាទៅវិញទៅមក។ យើងជឿថាសិស្សគ្រប់រូបមានសិទ្ធិ និងសមត្ថភាពក្នុងការរៀន រីកចម្រើន និងរុងរឿងដូចគ្នា — ក្លាយទៅជាអ្នកសិក្សាពេញមួយជីវិត និងជាអ្នកចូលរួមចំណែកដ៏មានតម្លៃចំពោះសង្គមចម្រុះវប្បធម៌ និងសាមគ្គីគ្នា។

Chris Knight

នាយកសាលា



បាវចនារបស់យើង — ការថែទាំ ការតស៊ូ ការរៀនសូត្រ — បង្កើតជា "មាគ៌ារបស់វិទ្យាល័យវែលលីងតុន "Wellington Way" ដែលជាប្រពៃណីដ៏មានមោទនភាព ហើយដែលត្រូវបានទទួលស្គាល់ទាំងនៅក្នុងប្រទេស និងទាំងក្នុងអន្តរជាតិ។



ហេតុអ្វីត្រូវជ្រើសរើសវិទ្យាល័យវែលលីងតុន WELLINGTON SECONDARY COLLEGE?

អស់រយៈពេលជាង 20 ឆ្នាំមកហើយ កម្មវិធីសិស្សអន្តរជាតិរបស់យើងគឺជាផ្នែកដ៏សកម្ម និងមានតម្លៃរបស់វិទ្យាល័យ Wellington Secondary College ដែលស្វាគមន៍យ៉ាងកក់ក្តៅចំពោះនិស្សិតមកពីជុំវិញពិភពលោក។

យើងផ្តល់ជូននូវកម្មវិធីដ៏ទូលំទូលាយមួយ សេវាកម្មគាំទ្រដែលយកចិត្តទុកដាក់ និងទីកន្លែងដែលត្រូវបានបង្កើតឡើងដោយមានគោលបំណងច្បាស់លាស់ ដើម្បីធានាថាសិស្សអន្តរជាតិរបស់យើងមានអារម្មណ៍ដូចនៅផ្ទះរបស់ខ្លួន និងសម្រេចបាននូវអ្វីដែលជារបស់ពួកគេឱ្យបានល្អបំផុត។ ទាំងនេះរួមមាន៖ ក្រមកម្មវិធីអន្តរជាតិដែលមានបទពិសោធន៍ និងចំណង់ចំណូលចិត្តបំពេញការងារខ្ពស់។

- ក្រមកម្មវិធីអន្តរជាតិដែលមានបទពិសោធន៍ និងចំណង់ចំណូលចិត្តបំពេញការងារខ្ពស់។
- ជំនួយការពហុវប្បធម៌ និងគ្រូបង្រៀនដែលចេះពីរភាសា ដើម្បីគាំទ្រការបន្សាំ និងបញ្ចូលខ្លួនទៅក្នុងជីវិតនៃសង្គមអូស្ត្រាលី
- កម្មវិធីភាសាអង់គ្លេសជាភាសាបន្ថែម (EAL) ដែលមានធនធានល្អ
- ការធ្វើបច្ចុប្បន្នភាពជាប្រចាំ កម្មវិធីផ្តល់ព័ត៌មាន និងចែករំលែករបបថតជាមួយឪពុកម្តាយ និងភ្នាក់ងារ ដើម្បីរក្សាទំនាក់ទំនងរបស់ពួកគេ។
- កំណត់ត្រាល្អិតល្អន់នៃភាពជោគជ័យរបស់សិស្សអន្តរជាតិក្នុងការទទួលការបន្តការសិក្សានៅសាកលវិទ្យាល័យ

ការប្តេជ្ញាចិត្តរបស់យើងធានាឱ្យសិស្សអន្តរជាតិគ្រប់រូបទទួលបានការគាំទ្រ បំផុសគំនិត និងកំណត់មាគ៌ាច្បាស់លាស់មួយឆ្ពោះទៅកាន់ភាពជោគជ័យក្នុងការសិក្សា និងជីវិតផ្ទាល់ខ្លួន។

កម្មវិធីសិក្សាផ្លូវការដែលរៀបចំទៅតាមទេពកោសល្យរបស់សិស្សម្នាក់ៗ

ការអនុវត្តការបង្រៀន និងការរៀនរបស់យើងត្រូវបានបង្កើតឡើងជុំវិញអក្សរស៊ីប៊ូន (4c)៖

- ការត្រិះរិះពិចារណា Critical thinking
- ការដោះស្រាយបញ្ហាប្រកបដោយភាពច្នៃប្រឌិត Creative problem-solving
- ទំនាក់ទំនង Communication
- កិច្ចសហការ Collaboration

យើងផ្តល់ជូននូវមុខវិជ្ជាជាច្រើនសម្រាប់កម្មវិធីសិក្សាដើម្បីទទួលវិញ្ញាបនបត្រសិក្សារបស់រដ្ឋវិចថូរៀ ព្រមទាំងមុខវិជ្ជាចម្បងរបស់រដ្ឋវិចថូរៀ (VM) ដែលអនុញ្ញាតឱ្យសិស្សបង្កើតកម្មវិធីសិក្សាថ្នាក់ខ្ពស់ ដែលមានលក្ខណៈបុគ្គល និងទូលំទូលាយ។ កម្មវិធីបែបនេះត្រូវបានបង្កើតឡើងក្នុងភាពជាដៃគូជាមួយអ្នកសម្របសម្រួលសាលាថ្នាក់ខ្ពស់ ក្រុមការងារ និងមធ្យោបាយ ក្រុមការងារសុខុមាលភាព និងគ្រូប្រចាំថ្នាក់របស់យើង។

កម្មវិធីឈ្មោះ High Flyers របស់យើងគឺជាកម្មវិធីជ្រើសរើសសិស្ស ចូលរៀនរយៈពេល 3 ឆ្នាំ (ថ្នាក់ទី 7 ដល់ទី 9) ក្នុងមុខវិជ្ជាស្នូល ដែលត្រូវបានបង្កើតឡើងដើម្បីរៀបចំសិស្សសម្រាប់ជីវិតនៅក្នុងសហគមន៍ពិភពលោក ឱ្យក្លាយជាបុគ្គលមានចិត្តប្រឹងប្រែង និងជាអ្នកសិក្សាពេញមួយជីវិត។

កម្មវិធីវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) របស់យើងលើកទឹកចិត្តសិស្សឱ្យចេះគិតស៊ីជម្រៅ និងប្រកបដោយភាពច្នៃប្រឌិត និងធ្វើទំនាក់ទំនងរវាងគំនិតនៅគ្រប់មុខវិជ្ជាទាំងអស់។ មជ្ឈមណ្ឌល STEM ដែលបង្កើតឡើងប្រកបដោយគោលបំណងថ្មី បានបើកនៅចុងឆ្នាំ 2022 បានជំរុញបរិយាកាសសហការ និងជាកន្លែងសម្រាប់បច្ចេកវិទ្យាឌីជីថល និងការរចនា។

យើងក៏ផ្តល់ជូនក្លឹបសិក្សាសម្រាប់កិច្ចការដែលគ្រូដាក់ឱ្យធ្វើ Homework Clubs នៅពេលអាហារថ្ងៃត្រង់ និងក្រោយពេលរៀន ដោយផ្តល់នូវការគាំទ្របន្ថែមលើមុខវិជ្ជាជាច្រើន ដើម្បីជួយសិស្សគ្រប់រូបឱ្យឈានដល់សក្តានុពលរបស់ពួកគេ។





ជម្រើសដ៏ល្អនៃសកម្មភាពក្រៅកម្មវិធីសិក្សា

សិស្សត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងសកម្មភាពក្រៅថ្នាក់រៀន ដើម្បីបង្កើតទំនុកចិត្តលើភាសាអង់គ្លេស និងបង្កើតមិត្តភាពថ្មី។

ឱកាសរួមមាន៖

- ការបោះជំរុំ ដំណើរកំសាន្តសិក្សានៅក្រៅសាលា និងនៅក្នុងសាលា
- ការលេងហ្គេម ការប្រកួត និងព្រឹត្តិការណ៍រៃអង្គាសប្រាក់
- ការប្រគុំតន្ត្រីដោយប្រើឧបករណ៍ភ្លេង
- កីឡា រួមមាន បាល់ទះ បាល់បោះ វាយកូនឃ្លីលើតុ វាយសី និងបាល់ទាត់
- តួនាទីជាអ្នកដឹកនាំរបស់សិស្សនៅទូទាំងវិទ្យាល័យ
- ក្លឹបធ្វើលំហាត់ក្រោយម៉ោងសិក្សា និងនៅពេលអាហារថ្ងៃត្រង់
- កម្មវិធីតម្រង់ទិសដ៏ទូលំទូលាយ
- ក្លឹបអាហារពេលព្រឹកដោយឥតគិតថ្លៃ

លំនៅដ្ឋាន Homestay ដែលជ្រើសរើសដោយមាតាបិតាសម្រាប់សិស្សអន្តរជាតិ

ថ្វីត្បិតតែវិទ្យាល័យពុំផ្តល់លំនៅដ្ឋាន Homestay ដល់សិស្សក៏ដោយ ក៏យើងទទួលយកសិស្សដែលជ្រើសរើសរស់នៅក្នុងលំនៅដ្ឋាន ដែលឪពុកម្តាយរបស់គេជាអ្នកជ្រើសរើសឱ្យផងដែរ។ លំនៅដ្ឋានទាំងនេះត្រូវបានត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ហើយការទៅឆែកត្រួតពិនិត្យត្រូវបានធ្វើឡើងជារៀងរាល់ 6 ខែម្តង។

ការធ្វើឱ្យមានសុខុមាលភាព និងការគាំទ្រជាអាទិភាព

សុខុមាលភាព និងសុភមង្គលរបស់សិស្សគ្រប់រូប គឺជាអាទិភាពចម្បងនៅវិទ្យាល័យវែលលីងតុន Wellington Secondary College ។ សិស្សានុសិស្សមានសិទ្ធិប្រើប្រាស់សេវាកម្មគាំទ្រជាច្រើន រួមមាន៖

- ជំនួយពហុវប្បធម៌
- ក្រុមគាំទ្រសហគមន៍
- ជំនួយសម្រាប់ការណាត់ជួបពេទ្យ
- ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងសុខុមាលភាព
- អ្នកប្រឹក្សាផ្តល់ការណែនាំអំពីអាជីព



ទីតាំងដែលអាចចូលបានយ៉ាងងាយស្រួល

Mulgrave គឺជាតំបន់លំនៅដ្ឋាននៅជាយក្រុងដ៏ស្ងប់ស្ងាត់មួយនៅភាគអាគ្នេយ៍នៃទីក្រុង Melbourne ដែលស្ថិតនៅចម្ងាយ 20 គីឡូម៉ែត្រពីកណ្តាលទីក្រុង និងនៅជិតសាកលវិទ្យាល័យម៉ូណាស្ស Monash ។

លក្ខណៈពិសេសរបស់តំបន់នេះរួមមាន មជ្ឈមណ្ឌលទំនិញ សួនច្បារ គោជនីយដ្ឋាន និងក្លឹបកីឡានានា។ វាក៏មានខ្សែឡានក្រុងដែលមានសេវាកម្មល្អផងដែរ ហើយក៏មានភាពងាយស្រួលក្នុងការធ្វើដំណើរទៅកាន់ស្ថានីយ៍រថភ្លើង ស្ត្រីងវែល Springvale និង ក្លែន វ៉េវើលី Glen Waverley ផងដែរ។



រឿងជោគជ័យថ្មីៗមួយ

វិសាល មកពីខេត្តសៀមរាប ប្រទេសកម្ពុជា បានសិក្សាភាសាអង់គ្លេស វិធីសាស្ត្រគណិតវិទ្យា គណិតវិទ្យាបន្ត ជីវិទ្យា គីមីវិទ្យា និងចិត្តសាស្ត្រ។ វិសាលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យម៉ូណាស្ស Monash ជាមួយបរិញ្ញាបត្រអប់រំ (កិត្តិយស) និងបរិញ្ញាបត្រវិទ្យាសាស្ត្រ។

ការមកប្រទេសអូស្ត្រាលីតែម្នាក់ឯងក្នុងថ្នាក់ទី 10 ពីប្រទេសកម្ពុជា គឺជាបញ្ហាប្រឈមដ៏ធំបំផុតមួយនៃជីវិតរបស់ខ្ញុំ។ ខ្ញុំរំពឹងថា វាពិបាក ឯកោ និងជ្រួលច្របល់ណាស់ — ប៉ុន្តែផ្ទុយទៅវិញ ខ្ញុំត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅ។ តាំងពីដំបូងម៉្លេះ ភាពកក់ក្តៅនៃសហគមន៍វិទ្យាល័យបានធ្វើឱ្យមានភាពខុសគ្នាពីការគិតរំពឹងទាំងអស់។ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងបុគ្គលិកទាំងអស់មានភាពរួសរាយរាក់ទាក់ និងគាំទ្រមិនគួរឱ្យជឿ។

វាគឺដោយសារតែចំណង់ចំណូលចិត្ត និងការយកចិត្តទុកដាក់របស់គ្រូវិទ្យាសាស្ត្រម្នាក់របស់ខ្ញុំ ដែលបានបំផុសគំនិតរបស់ខ្ញុំ ឱ្យបន្តអាជីពក្នុងការសិក្សាអប់រំវិទ្យាសាស្ត្រ។

ថ្ងៃនេះ បន្ទាប់ពីបញ្ចប់ការសិក្សារយៈពេល 4 ឆ្នាំនៅសាកលវិទ្យាល័យម៉ូណាស្ស Monash ខ្ញុំមានមោទនភាពក្នុងការនិយាយថា ខ្ញុំបានក្លាយជាគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រដោយខ្លួនឯង។ ខ្ញុំស្រឡាញ់ការងាររបស់ខ្ញុំ ហើយឥឡូវនេះខ្ញុំមានអារម្មណ៍ថាមានឯកសិទ្ធិក្នុងការដឹកនាំ និងបំផុសគំនិតដល់សិស្ស — ដូចគ្រូបង្រៀនរបស់ខ្ញុំធ្លាប់បានធ្វើមកលើខ្ញុំដែរ។ ដំណើររបស់ខ្ញុំបានចាប់ផ្តើមជាមួយនឹងការគាំទ្រដែលខ្ញុំបានទទួលក្នុងនាមជាសិស្សអន្តរជាតិ ហើយវាបានបណ្តុះមនុស្សម្នាក់ និងបង្កើតអ្នកអប់រំម្នាក់ ដែលនោះគឺជារូបខ្ញុំសព្វថ្ងៃនេះ។



ទំនាក់ទំនងមកសាលា

វិទ្យាល័យវែលលីងតុន

91 Police Road, Mulgrave Victoria 3170

អ្នកសម្របសម្រួលសិស្សអន្តរជាតិ– Catherine Reinhardt

ទូរសព្ទទំនាក់ទំនង៖ +61 3 9547 6822

អ៊ីមែល៖ wellington.sc@education.vic.gov.au

វិបសាយ៖ https://www.wellingtonsc.vic.edu.au/

Victorian Government Schools International Student Program

200 Victoria Parade, East Melbourne VIC 3002, Australia

Tel: +61 3 7022 1000
Email: international@education.vic.gov.au
Web: www.study.vic.gov.au

Published by the International Education Division

Department of Education Melbourne August 2025

© State of Victoria (Department of Education) 2025

CRICOS Provider Name and Code: Department of Education, 00861K